**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ :...០០៩...ប្រ.ក....ប.ស្ថ

# ប្រកាស
# ស្តីពី
# ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ «ជ្រោយស្វាយ» នៃតំបន់ប្រើប្រាស់ច្រើនយ៉ាង ស្ថិតក្នុងភូមិឈើនាង ភូមិសារាយ ភូមិស្រឡៅ ភូមិកំពង់ស្តាំ ភូមិជ្រោយស្វាយកើត និងភូមិជ្រោយស្វាយលិច ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង

## រដ្ឋមន្ត្រី ក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៩១៣/៩០៣/ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៤១៦/៣៦៨/ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំង
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញលិខិតចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ ស្តីពីការស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«ជ្រោយស្វាយ»**
- បានឃើញលិខិតចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការស្នើសុំបន្ថែមផ្ទៃដីព្រៃសហគមន៍តំបន់ការពារធម្មជាតិ **«ជ្រោយស្វាយ»**
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១._**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ **«ជ្រោយស្វាយ»** ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតនៅក្នុងភូមិឈើនាង ភូមិសារាយ ភូមិស្រឡៅ ភូមិកំពង់ស្តាំ ភូមិជ្រោយស្វាយកើត និងភូមិជ្រោយស្វាយលិច ឃុំដងពែង និងភូមិចំការក្រោម ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង។

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ **«ជ្រោយស្វាយ»** នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង មានផ្ទៃដីទំហំ ៥២២ ហិកតា(ប្រាំរយម្ភៃពីរហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ និង មាននិយាមកា ( Datum: Indian_1960_UTM_Zone_48N) ដូចខាងក្រោម៖

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | ៣៦៣៨៨៥ | ១២២៣០៤៩ | 28 | ៣៥៩៥២១ | ១២២៣១៥៥ | 55 | ៣៥៩៥៣៤ | ១២២៣៩៤៤ |
| 2 | ៣៦៣៧៩៤ | ១២២៣១៥២ | 29 | ៣៥៨៩២៧ | ១២២២៩៧២ | 56 | ៣៦០១១៩ | ១២២៣៨០៥ |
| 3 | ៣៦៣៦៩៤ | ១២២៣២៣២ | 30 | ៣៥៨៣៦១ | ១២២៣០៦៤ | 57 | ៣៦០៨៦៥ | ១២២៣៧៦៨ |
| 4 | ៣៦៣២២៦ | ១២២៣៣៤៥ | 31 | ៣៥៨២២៥ | ១២២២៩៨០ | 58 | ៣៦១៦៦១ | ១២២៣៥៣៦ |
| 5 | ៣៦៣១០៦ | ១២២៣៣៨៥ | 32 | ៣៥៨៣៥៩ | ១២២២៧៨៤ | 59 | ៣៦២២៤២ | ១២២៣៧៣៥ |
| 6 | ៣៦២៩៥២ | ១២២៣៣៨៥ | 33 | ៣៥៨១៨១ | ១២២២៤៦៦ | 60 | ៣៦២៦៨៩ | ១២២៤០៥៩ |
| 7 | ៣៦២៩៨៨ | ១២២៣៤២៨ | 34 | ៣៥៧៩៣៦ | ១២២២៣៣៧ | 61 | ៣៦៣៧៧៩ | ១២២៣៣៤៩ |
| 8 | ៣៦២៩០០ | ១២២៣៤៣១ | 35 | ៣៥៦៦៨៩ | ១២២២២៩០ | 62 | ៣៦៣២៧៦ | ១២២៣៧៥១ |
| 9 | ៣៦២៥៦៣ | ១២២៣៣៣៨ | 36 | ២៥៦៤៨៤ | ១២២២២៦៤ | 63 | ៣៦៣១១៧ | ១២២៣៥៩៥ |
| 10 | ៣៦២៣១០ | ១២២៣៣០០ | 37 | ៣៥៦៤៨៤ | ១២២២២៣៦ | 64 | ៣៦៣៩៧០ | ១២២២៩៨២ |
| 11 | ៣៦២២៩១ | ១២២៣៤៥៧ | 38 | ៣៥៧៤៤៨ | ១២២១៧២២ | 65 | ៣៥៤២៥២ | ១២២២៦៦២ |
| 12 | ៣៦២១៨០ | ១២២៣៤២៤ | 39 | ៣៥៦៨៩៥ | ១២២១៧១៨ | 66 | ៣៥៣៧៦៥ | ១២២២៣៨៥ |
| 13 | ៣៦២២០៤ | ១២២៣២៤៤ | 40 | ៣៥៦៣៦០ | ១២២២២២២ | 67 | ៣៥២៧៤៥ | ១២២១៨០៥ |
| 14 | ៣៦១៦៤៣ | ១២២៣២៤៩ | 41 | ៣៥៦៣៤៩ | ១២២២៤៣១ | 68 | ៣៥២៧៤៤ | ១២២១៣៧០ |
| 15 | ៣៦១៦៦៩ | ១២២២៩៧៩ | 42 | ៣៥៦២៨២ | ១២២២៤៤៩ | 69 | ៣៥៣៣៦៨ | ១២២០៦២៥ |
| 16 | ៣៦១៦០៦ | ១២២២៩៣៣ | 43 | ៣៥៦២៦៨ | ១២២២៥៣៧ | 70 | ៣៥៣៥៦០ | ១២២០៧៦២ |
| 17 | ៣៦១៥១៧ | ១២២២៨៤៥ | 44 | ៣៥៦០៨៨ | ១២២២៥២១ | 71 | ៣៥៣៥៨២ | ១២២០៨៥៤ |
| 18 | ៣៦១៤៩៦ | ១២២២៦៨២ | 45 | ៣៥៥៦៨០ | ១២២២២២០ | 72 | ៣៥៣៧៤០ | ១២២០៩៧៣ |
| 19 | ៣៦១៤៤៤ | ១២២២៦៨៥ | 46 | ៣៥៥៧៩០ | ១២២២៦៣៥ | 73 | ៣៥៣៦៩៣ | ១២២១៥៦៤ |
| 20 | ៣៦១១៥៥ | ១២២២៥១១ | 47 | ៣៦២៦៨៩ | ១២២៤០៥៩ | 74 | ៣៥៣៩២១ | ១២២១៥៧៣ |
| 21 | ៣៦០៧៨៤ | ១២២២៧០៩ | 48 | ៣៦២២៤២ | ១២២៣៧៣៥ | 75 | ៣៥៣៩៤៩ | ១២២១៦៧៨ |
| 22 | ៣៦០៦០៤ | ១២២២៩៥៣ | 49 | ៣៦១៦៦១ | ១២២៣៥៣៦ | 76 | ៣៥៤០៦៣ | ១២២១៩០២ |
| 23 | ៣៦០៦៣៤ | ១២២៣៣៤១ | 50 | ៣៦១១៣៦ | ១២២៣២៧១ | 77 | ៣៥៤០៦០ | ១២២២១១៨ |
| 24 | ៣៦០៦០៦ | ១២២៣៣៥៦ | 51 | ៣៥៦៧២៧ | ១២២២៦២៦ | 78 | ៣៥៤០៦៥ | ១២២២២៤១ |
| 25 | ៣៦០១៧០ | ១២២៣១៣៤ | 52 | ៣៥៧៦៤៥ | ១២២២៩៣៧ | 79 | ៣៥៤១៥១ | ១២២២២៩០ |
| 26 | ៣៥៩៩១៨ | ១២២៣១៣៧ | 53 | ៣៥៧៧៣៩ | ១២២៣៣៩៨ | 80 | ៣៥៤៣៦៧ | ១២២២៣០២ |
| 27 | ៣៥៩៦៧៨ | ១២២៣១៥៧ | 54 | ៣៥៨៧១៩ | ១២២៣៥៥៦ | | | |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«ជ្រោយស្វាយ»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ **«ជ្រោយស្វាយ»** ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែងត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ **«ជ្រោយស្វាយ»** ត្រូវរៀបចំលក្ខន្តិកៈនិងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

អគ្គនាយក នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយក នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង នាយកតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង និងសហគមន៍តំបន់ការពារធម្មជាតិ**«ជ្រោយស្វាយ»**ត្រូវអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ មករា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

សាយ សំអាល់

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកោះកុង
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ